雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.170

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7885 ថ្ងៃសុក្រ ទី15 ខែមីនា ឆ្នាំ2019

## រដ្ឋាភិបាលចិននឹងសម្រេចការងារសំខាន់ចំនួន១០នៅឆ្នាំ២០១៩

ព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩ កិច្ចប្រជុំលើកទី២ នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិននីតិកាលទី១៣ បានបើកសម័យប្រជុំនៅវិមានសភាប្រជាជនចិន ក្នុងទីក្រុងប៉េកាំង។ ក្នុងនាមក្រុមប្រឹក្សាកិច្ចការរដ្ឋចិន ឯកឧត្តម លី ខឺឈាំង នាយករដ្ឋមន្ត្រីចិន បានអញ្ជើញឡើងធ្វើរបាយការណ៍ការងារនៃរដ្ឋាភិបាលចិនក្នុងកិច្ចប្រជុំនេះ ។

ឯកឧត្តម មានប្រសាសន៍ថា គោលដៅសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចនៅឆ្នាំ ២០១៩ គឺសម្រេចកំណើន GDP ៦-៦,៥ ភាគរយផ្តល់ការងារថ្មីដល់ប្រជាជនក្នុងទីក្រុងចំនួន១១លាននាក់ អត្រាអត់ការងារធ្វើដែលសិក្សាជាទូទៅមានកម្រិត ៥,៥ភាគរយ អត្រាអត់ការងារធ្វើដែលចុះបញ្ជីមានកម្រិតស្ថិតនៅក្រោម ៤,៥ ភាគរយអត្រាឡើងថ្លៃនៃទំនិញមានកម្រិតប្រហែល ៣ ភាគរយរក្សាជាទូទៅនូវតុល្យភាពរវាងចំណូលនិងចំណាយអន្តរជាតិពាណិជ្ជកម្មអាហារ័ណ នីហរ័ណមានការអភិវឌ្ឍន៍ដោយស្ថិរភាពរក្សាអត្រា Macro Leverage Rate ឱ្យមានស្ថិរភាពជាទូទៅគ្រប់គ្រងដោយមានប្រសិទ្ធភាពនូវហានិភ័យហិរញ្ញវត្ថុកាត់បន្ថយជនក្រីក្រតាមទីជនបទជាង១០លាននាក់សម្រេចការបង្កើនចំណូលប្រជាជននិងការអភិវឌ្ឍសេដ្ឋកិច្ច ដោយព្រមពេលជាមួយគ្នាកែលម្អបន្ថែមទៀតនូវអេកូ-បរិស្ថានការប្រើប្រាស់ថាមពលធៀបនឹងទំហំ GDP ធ្លាក់ចុះ៣ ភាគរយបន្តកាត់បន្ថយនូវការបញ្ចេញជាតិបំពុលបរិស្ថានសំខាន់ ។



នៅថ្ងៃទី ៥ ខែមីនា កិច្ចប្រជុំលើកទី២នៃសភាតំណាង ប្រជាជនទូទាំងប្រទេសចិននីតិកាលទី១៣ បើកសម័យប្រជុំនៅវិមានសភា ប្រជាជនចិនក្នុងទីក្រុងប៉េកាំង

ឯកឧត្តមបានលើកឡើងក្នុងរបាយការណ៍ការងាររដ្ឋាភិបាលនេះថា នៅឆ្នាំ២០១៩ រដ្ឋាភិបាលចិននឹងផ្តល់អាទិភាពដល់ការងារសំខាន់និងចំណុចគន្លឹះដើម្បីសម្រេចនូវការងារចំនួន ១០ឱ្យបានល្អប្រសើរ រួមមាន១-បន្តធ្វើការច្នៃប្រឌិតនិងកែសម្រួលគោលនយោបាយគ្រប់គ្រងនិងសម្រួលជាទូទៅធានាឱ្យសេដ្ឋកិច្ចចិនស្ថិតនៅក្នុងចន្លោះសមហេតុផល ។ ២-បំផុសកម្លាំងរស់រវើកនៃតួអង្គសំខាន់តាមទីផ្សារខិតខំកែលម្អបរិស្ថានពាណិជ្ជកម្ម ។ ៣-ប្រកាន់ខ្ជាប់នូវគោលការណ៍ដែលធ្វើការអភិវឌ្ឍតាមការច្នៃប្រឌិតបង្កើតកម្លាំងចលករថ្មី ។ ៤-ជំរុញឱ្យបង្កើតជាទីផ្សារក្នុងស្រុកដ៏ខ្លាំងក្លាបន្តបញ្ចេញសក្តានុពលនៃតម្រូវការក្នុងស្រុក ។ ៥-បំពេញភារកិច្ចនៃការកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយខិតខំជំរុញការកាត់បន្ថយភាពក្រីក្រនិងការស្តារតំបន់ជនបទ ។ ៦-ជំរុញការអភិវឌ្ឍតំបន់ផ្សេងៗដោយសម្របសម្រួលគ្នាលើកកម្ពស់គុណភាពនៃការធ្វើនគរូបនីយកម្មបែបទំនើប។ ៧-ផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងការបំពុលបរិស្ថាននិងការការពារអេកូ-បរិស្ថានខិតខំជំរុញការអភិវឌ្ឍដោយបៃតង ។ ៨-ធ្វើឱ្យកាន់តែស៊ីជម្រៅនូវកំណែទម្រង់លើវិស័យសំខាន់ពន្លឿនការកែសម្រួលយន្តការទីផ្សារ ។ ៩-ជំរុញការបើកចំហគ្រប់ជ្រុងជ្រោយបង្កើនឧត្តមភាពថ្មីនៃការធ្វើកិច្ចសហប្រតិបត្តិការនិងការប្រកួតប្រជែងអន្តរជាតិ ។ ១០-បង្កើនល្បឿននៃការអភិវឌ្ឍបុព្វហេតុសង្គម-និយម ធានានិងកែលម្អជីវភាពរស់នៅរបស់ប្រជាជន ។

ក្នុងឱកាសនេះ ឯកឧត្តមក៏បានបកស្រាយអំពីការពង្រឹងសមត្ថភាពរដ្ឋាភិបាលការងារអំពីជនជាតិភាគតិចសាសនានិងអាណិកជនចិន ការកសាងសមត្ថភាពការពារជាតិនិងកងទ័ពការអភិវឌ្ឍន៍នៃតំបន់ហុងកុងនិងម៉ាកាវ ទំនាក់ទំនងរវាងតំបន់ចិនដីគោកនិងតៃវ៉ាន់និងគោលនយោ-បាយការទូតរបស់ប្រទេសចិន ៕

## សង្ឃឹមថា"ស្ពានក្នុងសុបិន" នឹងអាចសាងសង់រួចរាល់ក្នុងពេលឆាប់ៗ

បច្ចុប្បន្ន ស្ពានស្ទឹងត្រង់-ក្រូចឆ្មារ ដែលមានទីតាំងស្ថិតនៅទីប្រសព្វគ្នារវាងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កំពុងតែដំណើរការសាងសង់ ។ គម្រោងស្ពានស្ទឹងត្រង់-ក្រូចឆ្មារនេះបានបើកការដ្ឋានសាងសង់ជាផ្លូវការនៅខែធ្នូឆ្នាំ២០១៧ ដែលនឹងអាចផ្តល់ការងាយស្រួលដល់ប្រជាជនខ្មែរក្នុងការធ្វើដំណើរពីភូមិភាគកណ្តាលនិងខាងជើងទៅកាន់ភាគខាងកើតនៃប្រទេសកម្ពុជា ។ ស្ពានធំនេះបានត្រូវប្រជាជនខ្មែរវាយតម្លៃថាជា"ស្ពានក្នុងសុបិន"សម្រាប់ការអភិវឌ្ឍនៃភូមិភាគកណ្តាលនិងខាងជើងប្រទេសកម្ពុជា ។



ការដ្ឋានសាងសង់ ស្ពានស្ទឹងត្រង់-ក្រូចឆ្មារ

គម្រោងស្ពានស្ទឹងត្រង់-ក្រូចឆ្មារនេះកំពុងដំណើរការសាងសង់ដោយក្រុមហ៊ុនស្ថាបត្យកម្មក្រុង សៀងហៃ ក្រោមការគាំទ្រពីប្រាក់ឥណទានអនុគ្រោះរបស់ប្រទេសចិន ។ គម្រោងនេះមានស្ពានធំនិង ផ្លូវថ្នល់ដែលមានប្រវែងសរុប៩,៨គីឡូម៉ែត្រក្នុងនោះមានតួស្ពាន ១.១៣១ ម៉ែត្រ ។

លោកចាំង ហួម៉េង នាយកប្រតិបត្តិនៃគម្រោងស្ពានស្ទឹងត្រង់-ក្រូចឆ្មារ បានប្រាប់អ្នកកាសែតថាទោះបីជារាជរដ្ឋាភិបាលឬសង្គមស៊ីវិលនៅប្រទេសកម្ពុជាសុទ្ធតែសង្ឃឹមថាស្ពានធំនេះនឹងអាចត្រូវដាក់ឱ្យ ប្រើ-ប្រាស់ក្នុងពេលឆាប់ៗ ។ សព្វថ្ងៃ យើងកំពុងដំណើរការសាងសង់ទាំង ២៤ម៉ោង។ បើដំណើរការសាងសង់បានរលូនស្ពានធំនេះនឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅចុងឆ្នាំ២០២០។

តាមការណែនាំបានឱ្យដឹង ថា បើធ្វើដំណើរពីខេត្តស្ទឹងត្រែងទៅខេត្តកំពង់ចាម ដោយឆ្លងទន្លេមេគង្គមានស្ពានតែ ២ខ្សែ តែជួនកាលត្រូវធ្វើដំណើរយ៉ាងឆ្ងាយ ដើម្បីឆ្លងទន្លេតាមស្ពានទាំងពីរខ្សែ ។ ដូច្នេះស្ពានស្ទឹងត្រង់-ក្រូចឆ្មារនេះនឹងអាចផ្តល់ការងាយស្រួលដល់ប្រជាជនខ្មែរក្នុងការធ្វើដំណើរទៅ មករវាងខេត្តទាំងពីរ និងមានសារសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៃតំបន់ កណ្តាលនិងខាងជើងនៃប្រទេសកម្ពុជា ។

លោក ស៊ីនគួស្ទួន អគ្គនាយករងនៃក្រុមហ៊ុនស្ថាបត្យកម្មក្រុង សៀង-ហៃសាខាកម្ពុជាបានបញ្ជាក់ថា តាំងពីឆ្នាំ២០០៤មកក្រុមហ៊ុនយើងខ្ញុំបានទទួលបន្ទុកអនុវត្តន៍គម្រោងចំនួន ២១នៅប្រទេសកម្ពុជាដែល បានសាងសង់ផ្លូវថ្នល់១.៧៥៨ គីឡូម៉ែត្រ និងស្ពានធំ ៦ខ្សែ ដែល មានប្រវែងសរុប ៦.៧៧៩ ម៉ែត្រ ។ យើងបានចំណាយពេលច្រើន និងខិតខំអស់ពីសមត្ថភាពក្នុងការកំណត់ផែនការនិងអនុវត្តន៍គម្រោងនីមួយៗដើម្បីធានាឱ្យគម្រោងទាំងអស់អាចក្លាយជាគម្រោងគំរូនៃកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះរវាងប្រទេសទាំងពីរចិននិងកម្ពុជា ។

សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា ប្រទេសចិនបានផ្តល់ជំនួយឧបត្ថម្ភជាក់ស្តែងដល់កម្ពុជា ហើយបានទទួលលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ។ ឯកឧត្តម ប្រាក់-សុខុន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហ-ប្រតិបត្តិការអន្តរជាតិកម្ពុជាបានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថាស្ពានទាំងអស់សុទ្ធតែជានិមិត្តសញ្ញានៃមិត្តភាពកម្ពុជា-ចិន ។ ចំណងមិត្ត-ភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជានិងចិនរួមមានក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការក្រោមគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយនិងផ្លូវមួយ" មុខជានឹងអាចធ្វើឱ្យសេដ្ឋកិច្ចនិងសង្គមនៃប្រទេសទាំងពីរទទួលបាននូវការរីកចម្រើនកាន់តែច្រើនព្រមទាំងរួមវិភាគទានក្នុងការកសាងសហគមន៍រួមវាសនាមនុស្សជាតិដែលមានភាពរុងរឿងថ្កុំថ្កើងនិងប្រកបដោយសុខដុមរមនា ៕

### មិត្តអ្នកអាន ជាទីរាប់អាន:

សូមថ្លែងអំណរគុណជូនចំពោះលោកអ្នកដែលបានយកចិត្តទុកដាក់ចំពោះទំព័រកាសែត"ខេត្តយូនណានប្រទេសចិន"។ ក្នុងគោលបំណងផ្តល់ជូនលោកអ្នកនូវព័ត៌មានអំពីគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយនិងផ្លូវមួយ"សូមលោកអ្នកផ្តល់យោ-បល់ដ៏មានតម្លៃដល់យើងខ្ញុំ ។ សូមសួរថា តើលោកអ្នកចង់ស្វែងយល់អំពីព័ត៌មានអ្វីខ្លះដែលមានពាក់ព័ន្ធទៅនឹង"ខ្សែក្រវាត់មួយនិងផ្លូវមួយ"? តើយើងខ្ញុំត្រូវកែសម្រួលការងារដូចម្តេចដើម្បីផ្សព្វផ្សាយ"ខ្សែក្រវាត់មួយនិងផ្លូវមួយ"ឱ្យបានកាន់តែល្អប្រសើរ ? តើយើងខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីជំរុញឱ្យការផ្សាយព័ត៌មានអំពី"ខ្សែក្រវាត់មួយនិងផ្លូវមួយ"មានតម្លៃកាន់តែខ្ពស់និងមានកម្លាំងទាក់ទាញកាន់តែខ្លាំង ? បើលោកអ្នកមានយោបល់អ្វីអំពីបញ្ហាខាងលើ ឬក៏មានយោបល់ពាក់ព័ន្ធផ្សេងៗទៀត សូមទាក់ទងជាមួយយើង ខ្ញុំតាមអ៊ីម៉ែល385604437@qq.com ។ សូមអរគុណ !

ផ្នែកនិពន្ធទំព័រកាសែត "ខេត្តយូណានប្រទេសចិន"

## ធនាគារជាតិមីយ៉ាន់ម៉ាចាត់ទុកប្រាក់យ៉ានចិនជារូបិយវត្ថុទូទាត់អន្តរជាតិជាផ្លូវការ

ពេលថ្មីៗនេះ ធនាគារជាតិមីយ៉ាន់ម៉ា បានប្រកាសឱ្យប្រើប្រាស់ប្រាក់យ៉ានចិននិងប្រាក់យ៉េនជប៉ុនជារូបិយវត្ថុទូទាត់អន្តរជាតិជាផ្លូវការ ។

តាមសេចក្តីប្រកាសនៃធនាគរជាតិមីយ៉ាន់ម៉ាបានឱ្យដឹងថា ប្រទេសមីយ៉ាន់ម៉ា អនុញ្ញាតឱ្យប្រើ ប្រាស់ប្រាក់យ៉ានចិននិងប្រាក់យ៉េនជប៉ុនជារូបិយវត្ថុទូទាត់អន្តរជាតិ ជាផ្លូវការដើម្បីជំរុញការអភិវឌ្ឍ ប្រព័ន្ធទូទាត់អន្តរជាតិនិងពាណិជ្ជកម្មតាមតំបន់ព្រំដែននៃប្រទេសមីយ៉ាន់ម៉ា ។ ក្រៅពីធនាគារដែលបានទទួលការអនុញ្ញាតធនាគារជាតិមីយ៉ាន់ម៉ាមិនអនុញ្ញាតជាបណ្តោះអាសន្នឱ្យស្ថាប័នឬបុគ្គលផ្សេងទៀតបង្កើតគណនីប្រាក់យ៉ានចិននិង ប្រាក់យ៉េនជប៉ុន ។

អ្នកទទួលខុសត្រូវមួយរូបនៃធនាគារជាតិមីយ៉ាន់ម៉ាបានធ្វើបទឧទ្ទេសនាមថា ការអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់យ៉ានចិនជារូបិយវត្ថុទូទាត់អន្តរជាតិនឹងផ្តល់ការងាយស្រួលដល់ការទូទាត់នៃពាណិជ្ជកម្មតាមតំបន់ព្រំដែនចិននិងមីយ៉ាន់ម៉ា។ គួរបញ្ជាក់ថា មុននឹងនេះរូបិយវត្ថុទូទាត់អន្តរជាតិដែលទទួលការអនុញ្ញាតពីរដ្ឋាភិបាលមីយ៉ាន់ម៉ារួមមានប្រាក់អឺរ៉ូដុល្លារអាម៉េរិកនិងដុល្លារសិង្ហបុរី ៕ **ដោយជួង ប៉េនីងនិង ឈឺហុងលាំង**

## ប្រទេសចិនប្រមូលផលស្បៀងអាហារជាង៦សែនលានគីឡូក្រាមក្នុងរយៈពេលជាច្រើនឆ្នាំជាប់



កសិដ្ឋានទំនើបដែល មានលក្ខណៈពិសេសលើខ្ពង់រាបក្នុងទីក្រុងមីលឺមណ្ឌលស្វយ័តជនជាតិ ហានី និងជនជាតិយីហុងហឺខេត្ត យូនណាន (រូបថតដោយ ភូ ចាយ៉ុង កាសែតប្រជាជនដេលី)

ប្រទេសចិនជាប្រទេសកសិកម្មដ៏ធំមួយដែលមានប្រវត្តិ-សាស្ត្រដ៏យូរលង់ក្នុងការធ្វើកសិកម្មនិងសម្បូរទៅដោយវប្បធម៌កសិកម្មដ៏ត្រចះត្រចង់ ។ ទន្ទឹមនឹងការធ្វើកំណែទម្រង់លើវិស័យកសិកម្មកម្រិតទំនើបភាវូបនីយកម្មកសិកម្មនៃប្រទេសចិនត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ ។ កំណែទម្រង់ក្នុងតំបន់ជនបទចិនបានទទួលនូវសមិទ្ធផលថ្មីកាន់តែច្រើនចំណែកជីវភាពរស់នៅរបស់ប្រជាកសិករចិនក៏បានត្រូវកែលម្អជាច្រើនផងដែរ ។

តាមស្ថិតិប្រទេសចិនបានប្រមូលផលស្បៀងអាហារជាង៦សែនលានគីឡូក្រាម(ក្នុងមួយឆ្នាំ) ក្នុងរយៈពេលជាច្រើនឆ្នាំជាប់គ្នាដែលបានកសាងមូលដ្ឋានគ្រឹះយ៉ាងរឹងមាំសម្រាប់ការអភិវឌ្ឍនៃវិស័យកសិកម្មនិងបានធ្វើឱ្យកសិករចិនមានជីវភាពរស់នៅកាន់តែល្អប្រសើរ ៕